**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ
## ផ្ញើជូន
## នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ
## ក្នុងទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៦

***មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា!***

ក្នុងឱកាសដ៏វិសេសវិសាល ពោរពេញដោយក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៦ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងខ្លួនខ្ញុំផ្ទាល់ សូមផ្ញើជូននូវសេចក្តីនឹករឭក យ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា សិក្ខាកាមកំពុងតែសិក្សាទាំងក្នុង និងក្រៅប្រទេស ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងមាំមួន និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជូនជាតិមាតុភូមិ។

ខ្ញុំសូមយកឱកាសដ៏មានអត្ថន័យនេះ សម្តែងនូវមោទនភាព និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដ៏ធំធេងដែលសម្រេចបានក្នុងឆ្នាំកន្លងមក អ្វីៗគ្រប់យ៉ាងដែលកងយោធពលខេមរភូមិន្ទយើងសម្រេចបាន គឺកើតចេញពីការលះបង់ ខិតខំពុះពារជម្នះគ្រប់ឧបសគ្គ និងការលំបាកនានា ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីការពារជាតិមាតុភូមិ ការពារសន្តិសុខជាតិ ស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីបានយ៉ាងគង់វង្សគ្រប់កាលៈទេសៈ ដើម្បីសេចក្តីសុខក្សេមក្សាន្តរបស់ជាតិ និងប្រជាជនកម្ពុជា។ ក្រោមឯកសណ្ឋានដ៏មានកិត្តិយសឧត្តុង្គឧត្តមនេះ កងយោធពលខេមរភូមិន្ទ បានរួមចំណែកយ៉ាងសកម្មក្នុងប្រតិបត្តិការជាប្រវត្តិសាស្ត្រទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ប្រកបដោយភាពអង់អាចក្លាហាន មោះមុត ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ ដើម្បីសម្រេចបាននូវជោគជ័យជូនជាតិមាតុភូមិគួរជាទីមោទនៈក្រៃលែង។

ជាថ្មីម្តងទៀត ក្នុងទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៦នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងខ្លួនខ្ញុំផ្ទាល់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល ជូនចំពោះមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញបេសកកម្ម និងសិក្ខាកាមទាំងអស់ដែលកំពុងសិក្សាជំនាញនានា រួមទាំងយោធិនដែលកំពុងសម្រាកព្យាបាលជំងឺនៅតាមមន្ទីរពេទ្យ ជាពិសេសវីរកងទ័ពដ៏អង់អាចក្លាហានទាំង ១៨រូប ដែលត្រូវបានទាហានថៃចាប់ឃុំខ្លួនដោយខុសច្បាប់ក្រោយបទឈប់បាញ់ សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងមាំមួន ឆាប់បានវិលត្រឡប់មកកាន់មាតុភូមិកំណើត ដើម្បីបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជូនជាតិមាតុភូមិនៃយើង។

សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃសុក្រ ១៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៤ email: generalsec@mod.gov.kh